**Declassified to Public**
**06 September 2012**



ឯកសារទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception): 10 / JUN / 2009
ម៉ោង (Time/Heure) : 10:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: CA.Ty

Jeffrey James

1045 Ranch Drive

Gardnerville NV USA 89460

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
ប្រអប់សំបុត្រលេខ៧១ ផ្លូវជាតិលេខ៤
សង្កាត់ចោមចៅ ខណ្ឌដង្កោ ភ្នំពេញ កម្ពុជា

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certiffied Date/Date de certification): 10 / 06 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

ថ្ងៃទី២៣ ខែមករា ឆ្នាំ២០០៩

**គោរពជូន: អស់លោក លោកស្រី**

ខ្ញុំសូមការអនុញ្ញាតដើម្បីដាក់សេចក្ដីថ្លែងការណ៍នេះបន្ថែមទៅលើផ្នែក “ខ” និង “គ” នៃទម្រង់បែបបទជនរងគ្រោះ ដែលមានភ្ជាប់មកជាមួយ។ ទម្រង់បែបបទនេះអនុវត្តចំពោះសំណុំរឿងលេខ១ ដែលទាក់ទងនឹងឧក្រិដ្ឋកម្មទាំងឡាយ បានប្រព្រឹត្តទាក់ទងនឹងមន្ទីរសន្តិសុខស-២១ (ទួលស្លែង) មន្ទីរសន្តិសុខស-២៤ និងការដ្ឋានជើងឯក ដែលត្រូវបានទទួលការចោទប្រកាន់ថាបានប្រព្រឹត្តដោយលោកកាំង ហ្កេកអ៊ាវ ហៅ ឌុច។

ខ្ញុំឈ្មោះ Jeffrey James។ ខ្ញុំជាជនជាតិអាមេរិកកាំង រស់នៅសហរដ្ឋអាមេរិក។ ម្ដាយរបស់ខ្ញុំឈ្មោះ Sherry A. Clark។ យោងតាមឯកសារនៅសារៈមន្ទីរប្រល័យពូជសាសន៍ទួលស្លែង និងឯកសារនៅឯYale Cambodian Genocide Project បងប្រុសម្ដាយខ្ញុំ (ត្រូវជាពូខ្ញុំ) ឈ្មោះ James W. Clark ត្រូវបានគេចាប់ខ្លួននៅឆ្នេរសមុទ្រកម្ពុជាក្នុងខែមេសា ឆ្នាំ១៩៧៨។ បន្ទាប់មក James ត្រូវបានគេនាំយកទៅគុកទួលស្លែង(ស-២១) ធ្វើទារុណកម្មបង្ខំឱ្យឆ្លើយប្រឌិតរឿង ទាក់ទងនឹងCIA អាមេរិក ហើយបន្ទាប់មកទៀត ត្រូវបានគេសម្លាប់។ គេមិនដែលបានឃើញសាកសពរបស់គាត់ទេ។ យោងតាមអតីតឆ្មាំម្នាក់នៅគុកទួលស្លែងថា សាកសពរបស់គាត់ត្រូវបានគេដុត “ដូច្នេះអត់មានឆ្អឹងទេ”។

ពីដំបូងខ្ញុំបានដឹងនូវឧក្រិដ្ឋកម្មទាំងឡាយប្រព្រឹត្តឡើងចំពោះពូរបស់ខ្ញុំ James Clark ក្នុងឆ្នាំ១៩៨០ នៅពេលដែលខ្ញុំមានអាយុ១០ឆ្នាំ។ ខ្ញុំចាំបានពីការអានអត្ថបទមួយក្នុងទស្សនាវដ្ដីឈ្មោះ Life

Magazine (ខែមីនា ឆ្នាំ១៩៨០) ដោយ Steve Robinson រៀបរាប់អំពីអំពើព្រៃផ្សៃងបានប្រព្រឹត្ត ឡើងចំពោះពូខ្ញុំ។ អត្ថបទនោះគឺពោរពេញទៅដោយរូបថត ដែលពូខ្ញុំត្រូវគេរៀបរាប់ថា ត្រូវគេវាយ និង បង្អត់អាហារ។ ព័ត៌មានដែលបានលើកឡើងនៅក្នុងអត្ថបទទទួលបានមកពីឯកសារគុកទួលស្លែង។ ព័ត៌មាននេះគឺថិតនៅក្នុងឯកសារគុក។ សៀវភៅមួយចំនួនត្រូវបានគេសរសេរទាក់ទងនឹងការចាប់ខ្លួន ការធ្វើទារុណកម្ម និងការសម្លាប់ពូខ្ញុំ សៀវភៅទាំងអស់នោះមានយោងឯកសារផ្លូវការ ដែលទទួល បានមកពីឯកសារគុកទួលស្លែង។

ខ្ញុំចាំបានច្បាស់ថា "ពូខ្ញុំឈ្មោះ Jim" មុនពេលគាត់ស្លាប់។ គាត់ឧស្សាហ៍មកលេងគ្រួសារ របស់យើងជាញឹកញាប់ណាស់ខណៈពេលខ្ញុំកំពុងធំដឹងក្តី។ យើងមានភាពស្និទស្នាលនឹងគ្នាខ្លាំង ណាស់។ ខ្ញុំតែងតែស្វែងរកគាត់ជានិច្ច។ ម្តាយខ្ញុំឈ្មោះ Sherry A. Clark បងប្រុសខ្ញុំឈ្មោះ Joshua Rothschild និងខ្ញុំខ្លួនឯងគឺគ្រាន់តែសាច់ញាតិរស់នៅរបស់ James Clark ប៉ុណ្ណោះ។

ព័ត៌មានពីស្តារអំពីការចាប់ខ្លួនគាត់ រឿងរ៉ាវនិងរូបថតនៃការធ្វើទារុណកម្ម និងការបង្អត់ អាហាររបស់គាត់ និងការសម្លាប់រូបគាត់ មានផលប៉ះពាល់យ៉ាងជ្រាលជ្រៅដល់រូបខ្ញុំ។ ខ្ញុំមិនអាចនឹក ស្រម៉ៃដល់របៀបដែលគេចាត់ទុកមនុស្សដូចគ្នាក្នុងលក្ខណៈមួយ ដែលគេបានធ្វើមកលើពូខ្ញុំទេ។ អំពើ ដែលមិនអាចថ្លែងបាន ដែលពូខ្ញុំត្រូវគេបង្ខំឱ្យទទួលរងគឺជាអំពើដែលមិនអាចអត់អោនឱ្យបានឡើយ។ ខ្ញុំនៅតែដេកភ្ញាក់នៅពេលយប់ ហើយស្រម៉ៃឃើញនូវភាពរន្ធត់ ដែលពូខ្ញុំបានឆ្លងកាត់។ ស្រម៉ៃ ឃើញរូបកាយរបស់គាត់ត្រូវគេវាយនៅក្នុងខួរក្បាលរបស់ខ្ញុំ។ បុគ្គលដែលទទួលខុសត្រូវចំពោះអំពើ ទាំងនេះ ត្រូវតែនាំយកមកតុលាការ។

ចំពោះហេតុផលទាំងឡាយបានរៀបរាប់ខាងលើ ដែលខ្ញុំចង់ក្លាយខ្លួនជាភាគីដើមបណ្តឹងរដ្ឋប្បវេណី ក្នុងសំណុំរឿងលេខ១ប្រឆាំងនឹងលោក កាំង ហ្កេក អ៊ាវ ហៅ ឌុច។ ខ្ញុំត្រៀមខ្លួនផ្តល់ភស្តុតាង ក្នុងទម្រង់ឯកសារគុក រូបថត និងចម្លើយផ្សេងទៀតគាំទ្រដល់ការចោទប្រកាន់របស់ខ្ញុំ។ ខ្ញុំក៏ត្រៀមខ្លួន ផងដែរក្នុងការថតចម្លងសំបុត្រកំណើត ដែលអាចបញ្ជាក់អំពីទំនាក់ទំនងខ្ញុំជាមួយ James Clark បាន។

ខ្ញុំដឹងថាមានប្រជាជនកម្ពុជាជាច្រើន ត្រូវទទួលរងនូវផលប៉ះពាល់យ៉ាងជ្រៅដោយឧក្រិដ្ឋកម្ម ទាំងឡាយ ដែលបានប្រព្រឹត្តឡើងដោយលោក កាំង ហ្កេកអ៊ាវ។ ខ្ញុំសង្ឃឹមថា លទ្ធផលនៃការជំនុំ ជម្រះនឹងនាំជនយកទាំងឡាយ ដែលទទួលខុសត្រូវចំពោះអំពើសាហាវព្រៃផ្សៃ ប្រឆាំងនឹងប្រជាជន កម្ពុជា និងអ្នកទាំងឡាយដែលប្រឆាំងនឹងពូរបស់ខ្ញុំ ទៅកាន់យុត្តិធម៌។ លើសពីនេះទៅទៀត ខ្ញុំសង្ឃឹម

ថា នៅពេលចប់សវនាការជំនុំជម្រះ ប្រជាជនកម្ពុជានឹងទទួលបានសិទ្ធិមនុស្ស ដែលពួកគេសមតែទទួលបាន។

សូមទទួលនូវការរាប់អានអំពីខ្ញុំ។

*ហត្ថលេខា*

Jeffrey James

**ចម្លងជូន**: Sarah Thomas